**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.[illegible]

រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការបង្កើតគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យា គម្រោងសេវាសន្តិសុខអាកាសចរណ៍

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**រដ្ឋមន្ត្រី**
**ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញលិខិតលេខ ១០២៣៦ សហវ.ល.ស.អរជ ចុះថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល

**សម្រេច**

**ប្រការ១.**

ត្រូវបានបង្កើតគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យាគម្រោងសេវាសន្តិសុខអាកាសចរណ៍ រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ) និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល (រលអស) ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **សរ មុន្នី** | រដ្ឋលេខាធិការ រលអស | សហប្រធាន |
| ២- ឯកឧត្តម **មាស សុខសេនសាន** | រដ្ឋលេខាធិការ កសហវ | សហប្រធាន |
| ៣- ឯកឧត្តម **ស៊ីន ចាន់សិរីវុត្ថា** | អនុរដ្ឋលេខាធិការ រលអស | អនុប្រធានប្រចាំការ |
| ៤- ឯកឧត្តម **ស៊ឹម ធីរៈ** | អនុរដ្ឋលេខាធិការ កសហវ | អនុប្រធាន |
| ៥- ឯកឧត្តម **ស៊ូ កិត្យា** | អនុរដ្ឋលេខាធិការ រលអស | សមាជិក |
| ៦- ឯកឧត្តម **ហូ លីហួច** | អនុរដ្ឋលេខាធិការ រលអស | សមាជិក |
| ៧- ឯកឧត្តម **ឱម ម៉ាក់ធារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូ រវាងរដ្ឋ និងឯកជន កសហវ | សមាជិក |
| ៨- ឯកឧត្តម **សេខ សត្ថា** | អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ រលអស | សមាជិក |
| ៩- ឯកឧត្តម **សារិន គុណ្ណាករ** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស រលអស | សមាជិក |
| ១០- ឯកឧត្តម **លឹម កៅ** | នាយកវិទ្យាស្ថានជាតិអាកាសចរណ៍ស៊ីវិល រលអស | សមាជិក |
| ១១- ឯកឧត្តម **ទ៉ាន់ ចន្ទី** | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយ និងបទប្បញ្ញត្តិដឹកជញ្ជូនតាមផ្លូវអាកាស រលអស | សមាជិក |
| ១២- លោក **ហ៊ាន ម៉ិនណិត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ កសហវ | សមាជិក |
| ១៣- លោក **កុយ សាវរិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ រលអស | សមាជិក/លេខាធិការ |
| ១៤- ឯកឧត្តម **ម៉ែន ចាន់នៅ** | ទីប្រឹក្សា និងជាប្រធាននាយកដ្ឋានរដ្ឋបាល និងគ្រប់គ្រងធនធានមនុស្ស រលអស | សមាជិក |

**ប្រការ២.**

គណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យា មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងគ្រប់គ្រងលើការត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោង និងកិច្ចសន្យាសេវាសន្តិសុខអាកាសចរណ៍ជាមួយក្រុមហ៊ុន Albans Management SA ជាដៃគូឯកជន និងក្រុមហ៊ុន ស៊ីឃ្យូរីធី អេវីអេសិន កម្ពុជា ឯ.ក (Security Aviation Kampuchea Co., Ltd) ជាក្រុមហ៊ុនមានគោលបំណងពិសេស សំដៅការធានាអនុលោមភាព និងកាតព្វកិច្ចរបស់គូភាគី ស្របតាម ខ និងលក្ខខណ្ឌនៃកិច្ចសន្យា ភ.រ.ជ
- បំពេញមុខងារជាយន្តការគ្រប់គ្រងកិច្ចសន្យាជាន់ខ្ពស់របស់រាជរដ្ឋាភិបាល សម្រាប់គម្រោងសេវាសន្តិសុខអាកាសចរណ៍ ក្នុងដំណាក់កាលប្រតិបត្តិការ ថែទាំ និងផ្ទេរ

- ពិនិត្យ និងសម្រេចលើរាល់បញ្ហាពាក់ព័ន្ធនឹងកិច្ចសន្យាគម្រោង លើកលែងបញ្ហាដែលទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ ដែលទាមទារការសម្រេចពីរដ្ឋមន្ត្រី កសហវ។ ក្នុងករណីមានវិវាទយឺតភាពត្រូវស្នើសុំការសម្រេចពីប្រមុខរាជរដ្ឋាភិបាល
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតចំណុះរាជរដ្ឋាភិបាល ដើម្បីដោះស្រាយសំណូមពរ និងបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យា ភ.រ.ជ ព្រមទាំងផ្តល់អនុសាសន៍ណែនាំដល់គ្រប់ភាគីពាក់ព័ន្ធ ដើម្បីបំពេញកាតព្វកិច្ច ដូចមានចែងក្នុងកិច្ចសន្យា ភ.រ.ជ
- មានសិទ្ធិបង្កើតអនុគណៈកម្មការ/ក្រុមការងារចំពោះកិច្ច ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍សម្រាប់ដោះស្រាយសំណូមពរ និងបញ្ហាជាក់លាក់ណាមួយ ក្នុងករណីចាំបាច់
- គ្រប់គ្រងសំណើកែសម្រួលកិច្ចសន្យា ភ.រ.ជ មុននឹងគោរពស្នើសុំការពិនិត្យ និងសម្រេចពីរដ្ឋមន្ត្រី រលអស និងកសហវ
- គ្រប់គ្រងលើការផ្លាស់ប្តូរទាំងឡាយណាក្នុងកិច្ចសន្យា ភ.រ.ជ រួមមានការបែងចែកហានិភ័យ, ការដោះស្រាយសំណង ឬវិវាទ និងដំណោះស្រាយផ្សេងៗទៀត រួមទាំងការរំលាយកិច្ចសន្យា។ ក្នុងករណីសំណើកែសម្រួលទាំងនោះមានផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និង/ឬផ្នែកសារពើពន្ធ ត្រូវលើកសំណើទាំងនោះជូនរដ្ឋមន្ត្រី កសហវ ដើម្បីពិនិត្យ និងសម្រេច
- រៀបចំកិច្ចប្រជុំពាក់ព័ន្ធ និងមានសិទ្ធិអញ្ជើញក្រុមហ៊ុន Albans Management SA ជាដៃគូឯកជន និងក្រុមហ៊ុនស៊ីយូរីធី អេរីអេសិន កម្ពុជា ឯ.ក ជំនាញការ/ទីប្រឹក្សាចូលរួមផ្តល់យោបល់លើបញ្ហា ឬការងារពាក់ព័ន្ធនឹងគម្រោង
- ពិនិត្យ និងអនុម័តលើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ និងរបាយការណ៍ពាក់ព័ន្ធផ្សេងៗទៀត
- ជាយន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកាតព្វកិច្ចផ្ទេរទ្រព្យសម្បត្តិគម្រោងរបស់ក្រុមហ៊ុនជូនរាជរដ្ឋាភិបាលតាម ខ និងលក្ខខណ្ឌនៃកិច្ចសន្យា
- បំពេញភារកិច្ចផ្សេងៗទៀតដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តគម្រោង តាមការចាំបាច់។

**ប្រការ៣.**

គណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យា មានអង្គភាពគ្រប់គ្រងគម្រោងជាលេខាធិការដ្ឋាន។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពគ្រប់គ្រងគម្រោង ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រី រលអស ។

**ប្រការ៤.**

អនុប្រធាន និងសមាជិកនៃគណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធាន រលអស ។ ក្នុងករណីចាំបាច់ គណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យាអាចអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀតពី កសហវ និង រលអស, ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ទីប្រឹក្សា និងជំនាញការឱ្យចូលរួមប្រជុំ តាមតម្រូវការ។

សហប្រធាន អាចប្រគល់សិទ្ធិឱ្យអនុប្រធានប្រចាំការដឹកនាំកិច្ចប្រជុំ តាមការចាំបាច់។

**ប្រការ៥.**

លេខាធិការដ្ឋានប្រើប្រាស់ថវិការដ្ឋ ឬប្រភពហិរញ្ញប្បទានស្របច្បាប់ផ្សេងៗទៀត សម្រាប់ទ្រទ្រង់កិច្ចដំណើរការរបស់គណៈកម្មាធិការសម្រាប់គ្រប់គ្រងកិច្ចសន្យា និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ដោយលើកសំណើមកកសហវ ដើម្បីពិនិត្យ និងសម្រេចតាមនីតិវិធីជាធរមាន។

**ប្រការ៦.**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧.**

អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃប្រកាសអន្តរក្រសួងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៨ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ២០២៣

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី** | **រដ្ឋមន្ត្រី** |
| **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល** |
| **អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** | **ម៉ៅ ហាវណ្ណាល់** |

**<u>កន្លែងទទួល៖</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ